កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

ចែកចាយ៖ទូទៅ
២៧ មេសា ២០១៥
សំណៅដើម៖ អង់គ្លេស

# គណៈកម្មាធិការសិទ្ធិមនុស្ស

## *សេចក្តីសង្កេតសន្និដ្ឋានលើរបាយការណ៍តាមកាលកំណត់លើកទីពីររបស់កម្ពុជា

១. គណៈកម្មាធិការសិទ្ធិមនុស្ស បានពិចារណារបាយការណ៍តាមកាលកំណត់លើកទីពីរ ដែលព្រះ រាជាណាចក្រកម្ពុជា បានដាក់ជូនគណៈកម្មាធិការ (CCPR/C/KHM/2) នាសម័យប្រជុំលើកទី ៣១៣៨ និង ៣១៣៩ របស់ខ្លួន (CCPR/C/SR.3138 and 3139) ដែលបានប្រារព្ធឡើងនៅថ្ងៃ ទី១៧ និងទី១៨ ខែមីនា ឆ្នាំ២០១៥។ នាសម័យប្រជុំលើកទី៣១៥៧ របស់ខ្លួន (CCPR/C/ SR. 3157) ដែលបានប្រារព្ធឡើងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ គណៈកម្មាធិការសិទ្ធិមនុស្ស បាន អនុម័តសេចក្តីសង្កេតសន្និដ្ឋានដូចខាងក្រោមនេះ។

## សេចក្តីផ្តើម

២. គណៈកម្មាធិការសិទ្ធិមនុស្ស ស្វាគមន៍ការដាក់របាយការណ៍តាមកាលកំណត់លើកទីពីរ របស់ កម្ពុជា ទោះជាមានការយឺតយ៉ាវរយៈពេល១០ឆ្នាំក្តី។ គណៈកម្មាធិការ សំដែងការកោតសរសើរ ចំពោះព័ត៌មានដែលមាននៅក្នុងរបាយការណ៍ និងសម្រាប់ឱកាសបន្តកិច្ចសន្ទនាប្រកបដោយន័យ ស្ថាបនារបស់ខ្លួនជាថ្មី ជាមួយគណៈប្រតិភូអន្តរក្រសួងរបស់រដ្ឋភាគី អំពីវិធានការផ្សេងៗដែលរដ្ឋ ភាគីបានចាត់នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍ ដើម្បីអនុវត្តបទប្បញ្ញត្តិនៃកតិកាសញ្ញា នេះ។ គណៈកម្មាធិការសូមវាយតំលៃខ្ពស់ចំពោះការឆ្លើយតបជាលាយលក្ខណ៍អក្សររបស់រដ្ឋភាគី(CCPR/C/KHM/Q/2/Add.1) ទៅនឹងបញ្ជីសំនួរដែលត្រូវបានបំពេញបន្ថែមដោយការឆ្លើយផ្ទាល់ មាត់ដោយគណៈប្រតិភូ។

*ត្រូវបានគណៈកម្មាធិការអនុម័ត នាសម័យប្រជុំលើកទី១១៣ របស់ខ្លួន (១៦ មីនា – ២ មេសា ២០១៥)។

## ចំណុចវិជ្ជមាន

៣. គណៈកម្មាធិការ ស្វាគមន៍ចំពោះវិធានការច្បាប់ និងវិធានការផ្លូវការទាំងឡាយដូចខាងក្រោម នេះ ដែលរដ្ឋភាគីបានចាត់៖

(ក) ការអនុម័តច្បាប់ស្តីពីការបង្ការអំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ នៅ ក្នុងខែកញ្ញា ឆ្នាំ២០០៥

(ខ) ការអនុម័តច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ នៅក្នុង ខែកុម្ភៈ ឆ្នាំ២០០៨ និង

(គ) ការអនុម័តច្បាប់ស្តីពីការការពារ និងការលើកស្ទួយសិទ្ធិជនពិការ នៅក្នុងខែឧសភា ឆ្នាំ ២០០៩។

៤. គណៈកម្មាធិការ ស្វាគមន៍ចំពោះការចូលជាសមាជិក ឬការផ្តល់សច្ចាប័នដោយរដ្ឋភាគីលើ លិខិតុបករណ៍អន្តរជាតិទាំងឡាយ ដូចខាងក្រោមនេះ៖

(ក) ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០២ និងស្តីពីការចូលរួមរបស់ កុមារនៅក្នុងជម្លោះប្រដាប់អាវុធ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤

(ខ) ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧

(គ) ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារី ភេទ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០

(ឃ) អនុសញ្ញាស្តីពីសិទ្ធិជនពិការ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ និង

(ង) អនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ នៅថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០១៣។

## ចំណុចសំខាន់ៗនៃកង្វល់ និងអនុសាសន៍

### ការអនុវត្តន៍កតិកាសញ្ញានៅថ្នាក់ជាតិ

៥. ទន្ទឹមនឹងកត់សំគាល់ឃើញថា សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ គឺជាផ្នែកមួយនៃច្បាប់កម្ពុជា ហើយដែលត្រូវអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជានោះ គណៈកម្មាធិការមានកង្វល់អំពី កម្រិតមានកំណត់ជាក់ស្តែងនៃការយល់ដឹងអំពីបទប្បញ្ញត្តិនៃកតិកាសញ្ញានេះ នៅក្នុងប្រព័ន្ធ តុលាការ ឬនៅក្នុង

វិជ្ជាជីវៈច្បាប់ ដែលជាលទ្ធផល មានករណីតិចតួចបំផុត ដែលតុលាការកម្ពុជា លើកមកសំអាង ឬប្រើប្រាស់បទប្បញ្ញត្តិនៃកតិកាសញ្ញានេះ។ (មាត្រា២)។

*រដ្ឋភាគី គួរចាត់វិធានការសមស្រប ដើម្បីលើកកម្ពស់ការយល់ដឹងអំពីកតិកាសញ្ញានេះ ក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា មេធាវី និងសាធារណៈជនទូទៅ ដើម្បី ធានាថា បទប្បញ្ញត្តិនៃកតិកាសញ្ញានេះ ត្រូវបានយកមកពិចារណានៅចំពោះមុខ តុលាការជាតិ។ ម្យ៉ាងវិញទៀត គណៈកម្មាធិការជម្រុញលើកទឹកចិត្តឲ្យរដ្ឋភាគី ចូលជាសមាជិកនៃពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ពាក់ព័ន្ធនឹងបណ្តឹងបុគ្គល។*

## *ស្ថាប័នជាតិសិទ្ធិមនុស្ស*

៦. ទទួ្ធមនឹងស្វាគមន៍ការណ៍ដែលថា មានសេចក្តីព្រាងច្បាប់មួយស្តីពីការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ដែលស្ថិតក្រោមការពិនិត្យនោះ គណៈកម្មាធិការមានការសោកស្តាយថាការបង្កើតស្ថាប័ន មួយនេះ មានការអូសបន្លាយពេលវេលាយូរអង្វែងពេក (មាត្រា២)។

*គណៈកម្មាធិការ ជម្រុញលើកទឹកចិត្តឲ្យរដ្ឋភាគី បង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ឯករាជ្យមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស (សេចក្តីសម្រេចចិត្តលេខ ៤៨/១៣៤ ឧបសម្ព័ន្ធ របស់មហាសន្និបាត)។*

## *សមភាពយេនឌ័រ*

៧. ទទួ្ធមនឹងស្វាគមន៍វិធានការទាំងឡាយ ដែលរដ្ឋភាគីបានចាត់ ដើម្បីបង្កើនការចូលរួមរបស់ស្ត្រី នៅក្នុងជីវភាពសាធារណៈ គណៈកម្មាធិការមានកង្វល់អំពីភាពជាតំណាងរបស់ស្ត្រីនៅមានកម្រិត ទាប នៅក្នុងវិស័យនយោបាយ និងវិស័យសាធារណ ជាពិសេស ក្នុងមុខតំណែងពាក់ព័ន្ធនឹងការធ្វើ សេចក្តីសម្រេចផ្សេងៗ។ គណៈកម្មាធិការ មានកង្វល់ផងដែរ អំពីគំនិតចាស់គំរិលដែលនៅតែមាន ទាក់ទងនឹងតួនាទីរបស់ស្ត្រីនៅក្នុងគ្រួសារនិងសង្គម អត្ថិភាពនៃគម្លាតប្រាក់ឈ្នួលដ៏គួរឲ្យកត់ សំគាល់ដោយសារយេនឌ័រ និងការប្រមូលផ្តុំស្ត្រីនៅក្នុងវិស័យកម្លាំងពលកម្មដែលគ្មានជំនាញ និង មានប្រាក់ឈ្នួលទាបរាប់ទាំងវិស័យឧស្សាហកម្មកាត់ដេរផងដែរ (មាត្រា២, ៣, និងមាត្រា២៦)។

*រដ្ឋភាគី គួរពង្រឹងវិធានការរបស់ខ្លួន ដើម្បីធានាសមភាពរវាងស្ត្រី និងបុរស នៅ គ្រប់វិស័យ រួមទាំងតាមរយៈការអនុវត្តន៍ឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត នូវច្បាប់ និងគោលនយោបាយពាក់ព័ន្ធនានា។ ក្នុងន័យនេះ រដ្ឋភាគីគួរបន្តអនុវត្ត វិធានការប*

*ណ្តោះអាសន្នពិសេស ដើម្បីបង្កើនការចូលរួមរបស់ស្ត្រី នៅក្នុងជីវភាព នយោបាយ និងសាធារណៈ។ រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បី បំបាត់គំនិតចាស់គំរិលខាងយេនឌ័រ សំដៅធ្វើការផ្លាស់ប្តូរទស្សនៈអំពីតួនាទីរបស់ ស្ត្រីនៅក្នុងសង្គម។ ម្យ៉ាងវិញទៀត រដ្ឋភាគីគួរចាត់វិធានការ ដើម្បីកាត់បន្ថយ គម្លាតប្រាក់ឈ្នួលទាក់ទងនឹងយេនឌ័រ និងការដោះស្រាយមូលហេតុទាំងអស់ សម្រាប់គម្លាតនោះ។*

*ការរើសអើងពូជសាសន៍*

៨. ទន្ទឹមនឹងគណៈកម្មាធិការ កត់សំគាល់អំពីការអះអាងរបស់រដ្ឋភាគីថា កម្ពុជាមិនរើសអើងចំពោះនរណាម្នាក់នោះ គណៈកម្មាធិការ នៅតែមានកង្វល់ចំពោះរបាយការណ៍អំពីសកម្មភាពរើសអើង និងអំពើហិង្សាលើជនជាតិភាគតិចវៀតណាម (មាត្រា២, ២៦ និងមាត្រា២៧)។

**រដ្ឋភាគីគួរពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងការវាយប្រហារ លក្ខណៈពូជសាសន៍និយម ប្រឆាំងនឹងជនជាតិភាគតិចវៀតណាម។ រដ្ឋភាគី គួរពិចារណា ផងដែរ អំពីការបង្កើតផែនការសកម្មភាពប្រឆាំងនឹងការរើសអើងពូជសាសន៍។**

*ការរើសអើងផ្អែកលើទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ*

៩. គណៈកម្មាធិការមានកង្វល់ផងដែរ ចំពោះរបាយការណ៍ស្តីពីការរើសអើងប្រឆាំងនឹងមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងមនុស្ស ប្តូរភេទ (LGBT) ជាពិសេសនៅកន្លែងធ្វើការ និងកន្លែងគាំពារសុខភាព។ គណៈកម្មាធិការ កត់ សំគាល់ដោយកង្វល់អំពីកង្វះច្បាប់ដែលហាមប្រាមការរើសអើង ដោយឈរលើហេតុផលនៃទំនោរ ផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ (មាត្រា២ និងមាត្រា២៦)។

*រដ្ឋភាគីគួរពិនិត្យឡើងវិញនូវច្បាប់របស់ខ្លួន ដើម្បីធានាថា ការរើសអើង ឈរលើ ហេតុផលនៃទំនោរផ្លូវភេទនិងអត្តសញ្ញាណយេនឌ័រ ត្រូវបានហាមឃាត់។ រដ្ឋភាគី គួរអនុវត្តផងដែរ នូវសកម្មភាពផ្សព្វផ្សាយការយល់ដឹងដល់សាធារណៈជន ដើម្បី ចូលរួមប្រយុទ្ធប្រឆាំងនឹងការរើសអើងសង្គមប្រឆាំងនឹងមនុស្សស្រីស្រលាញ់ភេទ ដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងមនុស្ស ប្តូរភេទ (LGBT)។*

*អំពើហឹង្សាទាក់ទងនឹងយេនឌ័រ*

១០. ទន្ទឹមនឹងកត់សំគាល់ឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋភាគី ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើ ហិង្សាលើស្ត្រីនៅកម្រិតធ្វើគោលនយោបាយ និងច្បាប់ គណៈកម្មាធិការមានកង្វល់ផងដែរពីចំនួន នៅទាបនៅឡើយនូវការកាត់ទោស និងការផ្តន្ទាទោសចំពោះអំពើហិង្សាយេនឌ័រ។ គណៈកម្មាធិ ការ មានការសោកស្តាយចំពោះកង្វះព័ត៌មាន ដែលរដ្ឋភាគីបានផ្តល់ឲ្យទាក់ទងនឹងសំណងដល់ជន រងគ្រោះដោយ

អំពើហិង្សាផ្លូវភេទ ដែលបានប្រព្រឹត្តនៅក្នុងអំឡុងរបបខ្មែរក្រហម ក៏ដូចជាការខ្វះ ព័ត៌មានស្តីពីការវាយតំលៃលទ្ធផលនៃផែនការសកម្មភាពថ្នាក់ជាតិ ដើម្បីបង្ការអំពើហិង្សាប្រឆាំង នឹងស្ត្រី (២០០៩-២០១២) (មាត្រា៣ និងមាត្រា៧)។

*រដ្ឋភាគី គួរធានាថា ករណីអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ ត្រូវបាន ធ្វើការស៊ើបអង្កេតឲ្យបានហ្មត់ចត់ ដែលជនដៃដល់ត្រូវបាននាំខ្លួនទៅផ្តន្ទាទោស តាមច្បាប់ ហើយផ្តល់សំណងគ្រប់គ្រាន់ដល់ជនរងគ្រោះ។ រដ្ឋភាគី គួរផ្តល់ផងដែរ នូវការបណ្តុះបណ្តាលចាំបាច់ដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការផ្សេងៗស្តីពី ការផ្តន្ទាទោសអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជួយសម្រួលដល់ជនរងគ្រោះ ក្នុងការស្វែងរកយុត្តិធម៌។*

## *និទណ្ឌភាពសម្រាប់ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ*

១១. គណៈកម្មាធិការមានកង្វល់ ដោយសេចក្តីរាយការណ៍ថា មិនមាននរណាម្នាក់ ទទួលខុសត្រូវចំពោះការសម្លាប់ក្រៅច្បាប់ ដែលគេអះអាងថា អំពើនេះត្រូវបានប្រព្រឹត្ត ជាពិសេស ដោយកងទ័ពនគរបាល និងកងរាជអាវុធហត្ថ នៅកម្ពុជា ចាប់តាំងពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ រហូតមក (មាត្រា៦)។

*គណៈកម្មាធិការ រំលឹកអំពីអនុសាសន៍កន្លងមករបស់ខ្លួន* (CCPR/C/79/Add.108, para. 11) *ថា រដ្ឋភាគីមានកាតព្វកិច្ចក្នុងការស៊ើបអង្កេតករណីទាំងអស់នេះ នូវការរំលោភសិទ្ធិមនុស្សកន្លងមក ការរំលោភបំពានជាពិសេសលើមាត្រា៦ នៃកតិកា សញ្ញានេះ ផ្តន្ទាទោសជនដៃដល់ ហើយប្រសិនជាសមស្រប ត្រូវដាក់ទោសទណ្ឌ ពួកគេ និងផ្តល់សំណងដល់គ្រួសារជនរងគ្រោះ។*

## *ការប្រើប្រាស់កម្លាំងហួសហេតុ*

១២. គណៈកម្មាធិការ មានកង្វល់ ដោយសេចក្តីរាយការណ៍អំពីករណីមនុស្សស្លាប់ រងរបួសច្រើន នាក់ និងមានមនុស្សម្នាក់បាត់ខ្លួនដោយបង្ខំ ក្រោយពីមានការបង្ក្រាបដោយកងកម្លាំងសន្តិសុខ នៅ ក្នុងអំឡុងពេលនៃបាតុកម្មនៅរាជធានីភ្នំពេញ ជាពិសេសនៅក្នុងអំឡុងពេលធ្វើបាតុកម្ម នៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៣ ការតវ៉ារបស់កម្មកររោងចក្រកាត់ដេរ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ និងការប្រមូលផ្តុំ ដែលបានធ្វើនៅថ្ងៃទី២-៣ ខែមករា ឆ្នាំ២០១៤។ គណៈកម្មាធិការ មានកង្វល់ បន្ថែមទៀតពីកង្វះព័ត៌មានលំអិតអំពីការស៊ើបអង្កេតលើករណីទាំងនេះ។ នៅចុងបញ្ចប់ គណៈកម្មា ធិការ នៅតែមានកង្វល់អំពីស្ថានភាពគតិយុត្តនៃកំលាំងសន្តិសុខសណ្តាប់ធ្នាប់ខណ្ឌ និងអំពីតួនាទី របស់ពួកគេ នៅក្នុងការយាមល្បាតបាតុកម្ម (មាត្រា៦, ៧ និងមាត្រា២១)។

*រដ្ឋភាគី គួរស៊ើបអង្កេតរាល់ការចោទប្រកាន់ទាក់ទងនឹងការប្រើកម្លាំងហួសហេតុ ជាពិសេស ការប្រើកម្លាំងប្រល័យដោយនគរបាល និងយោធា ហើយធានាថា ជន ដៃដល់ត្រូវបានកាត់ទោស និងផ្តល់សំណងគ្រប់គ្រាន់ដល់ជនរងគ្រោះ។ ម្យ៉ាងវិញ ទៀត រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីផ្តល់ការបណ្តុះបណ្តាល ជាប្រព័ន្ធដល់កម្លាំងសន្តិសុខទាំងអស់ រួមទាំង កំលាំងសន្តិសុខសណ្តាប់ធ្នាប់ ខណ្ឌផងដែរ អំពីការប្រើកម្លាំង ជាពិសេស ក្នុងបរិបទនៃការធ្វើបាតុកម្ម ដោយ គិតគូរឲ្យបានត្រឹមត្រូវអំពីគោលការណ៍របស់អង្គការសហប្រជាជាតិស្តីពីការប្រើ ប្រាស់កម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់។*

### *បំរាមការធ្វើទារុណកម្ម និងការប្រព្រឹត្តមិនគប្បី*

១៣. គណៈកម្មាធិការមានកង្វល់ដោយសេចក្តីរាយការណ៍អំពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមិនគប្បីលើជនជាប់ឃុំដោយមន្ត្រីអនុវត្តច្បាប់ ជាពិសេស ក្នុងបរិបទនៃការឃុំឃាំងរបស់នគរបាល និងសម្រាប់គោលបំណងនៃការទទួលបានចម្លើយសារភាព។ ក្នុងន័យនេះ គណៈកម្មាធិការ មានការសោកស្តាយចំពោះអវត្តមានទិន្នន័យទូទៅ និងតាមផ្នែកអំពីបណ្តឹង ការស៊ើបអង្កេត ការចោទ ប្រកាន់ និងការផ្តន្ទាទោស ក្នុងករណីនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តមិនគប្បី។ គណៈកម្មាធិ ការ មានកង្វល់ថា ចម្លើយសារភាពដែលបានមកពីការបង្ខិតបង្ខំ ឬការធ្វើទារុណកម្ម មិនអាចត្រូវ បានសម្រេចដោយមិនមានភស្តុតាង ហើយថា ចៅក្រមអាចប្រើប្រាស់ចម្លើយសារភាពបែបនេះ បាន លុះត្រាតែមានភស្តុតាងមកបញ្ជាក់ ក្នុងដំណើរការក្តីក្នុងតុលាការ។ គណៈកម្មាធិការ មាន កង្វល់បន្ថែមទៀតថា មិនមានអាជ្ញាធរទទួលពាក្យបណ្តឹងឯករាជ្យណាមួយដើម្បីទទួលដោះស្រាយ បណ្តឹងបែបនេះ ហើយក៏មិនមានប្រព័ន្ធណាមួយដែលមានប្រសិទ្ធភាព សម្រាប់បង្ការការធ្វើទារុណ កម្មនោះក៏ទេដែរ (មាត្រា៧, ១០ និងមាត្រា១៤)។

*រដ្ឋភាគី គួរបង្កើតយន្តការឯករាជ្យមួយ សម្រាប់ទទួលពាក្យបណ្តឹង ដែលមាន អំណាចស៊ើបអង្កេតរាល់ការចោទប្រកាន់ និងបណ្តឹងទាំងអស់ ទាក់ទងនឹងការធ្វើ ទារុណកម្ម និងការប្រព្រឹត្តមិនគប្បី។ រដ្ឋភាគី គួរធានាផងដែរថា ជនដៃដល់នៃបទ ល្មើសទាំងនេះ ត្រូវបានកាត់ទោស ហើយថា ជនរងគ្រោះ ត្រូវបានផ្តល់សំណង គ្រប់គ្រាន់។ រដ្ឋភាគី គួរចាត់វិធានការចាំបាច់ ដើម្បីធានាថា ចម្លើយសារភាពដែល បានមកពីការធ្វើ ទារុណកម្ម ឬការប្រព្រឹត្តមិនគប្បី មិនអាចយកជាការបានឡើយ នៅក្នុងតុលាការ ក្នុង គ្រប់ករណី ស្របតាមច្បាប់ជាតិរបស់ខ្លួន និងមាត្រា១៤ នៃ កតិកាសញ្ញានេះ។ ម្យ៉ាង វិញទៀត រដ្ឋភាគី គួរបង្កើតឲ្យបានឆាប់រហ័ស ឬដាក់ឲ្យ អនុវត្តយន្តការបង្ការថ្នាក់ជាតិ សម្រាប់បង្ការទារុណកម្ម ដូចមានចែងក្នុងពិធីសារ បន្ថែមនៃអនុសញ្ញាប្រឆាំង ទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯ ទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។*

*លក្ខខណ្ឌនៃការឃុំខ្លួន*

១៤. ទន្ទឹមនឹងស្វាគមន៍វិធានការផ្សេងៗដែលរដ្ឋភាគីបានចាត់ ដើម្បីធ្វើឲ្យប្រសើរឡើង ដល់លក្ខ ខណ្ឌនៃការឃុំខ្លួនក្នុងពន្ធនាគារ គណៈកម្មាធិការ កត់សំគាល់ដោយកង្វល់ពី ការដាក់អ្នកទោស ច្រើនហួសចំណុច សេវាគាំពារសុខភាពមិនគ្រប់គ្រាន់ រួមទាំងការខ្វះអាគារពន្ធនាគារ សម្រាប់ដាក់ ជនជាប់ឃុំដែលមានបញ្ហាសុខភាពផ្លូវចិត្ត និងពីការកាត់បន្ថយរយៈពេលសម្រាប់ជនជាប់ឃុំ ចេញ ក្រៅបន្ទប់ឃុំឃាំង ដើម្បីធ្វើលំហាត់ប្រាណជាប្រចាំថ្ងៃ ដែលការណ៍នេះ នៅតែជាបញ្ហាដដែលនៅ ក្នុងប្រព័ន្ធពន្ធនាគារ។ គណៈកម្មាធិការ មានកង្វល់ផងដែរ អំពីការអះអាងថាមានការប្រព្រឹត្តអំពើ ពុករលួយ នៅក្នុងស្ថាប័នពន្ធនាគារ។ គណៈកម្មាធិការ សម្តែងកង្វល់របស់ខ្លួន អំពីរយៈពេលវែង នៃការឃុំខ្លួនមុនសវនាការ និងការបង្ខាំងអ្នកទោសដោយបំពាន បន្ទាប់ពីពួកគេបានបំពេញចប់ រយៈទោសហើយនោះ ដោយសារតែសាលក្រមស្ថាពរ មិនត្រូវបានទំនាក់ទំនង ឬបញ្ជូនទៅអាជ្ញា ធរពន្ធនាគារ (មាត្រា៩ និងមាត្រា១០)។

> *រដ្ឋភាគី គួរអនុម័តវិធានការមានប្រសិទ្ធភាព ដើម្បីកាត់បន្ថយចំនួនអ្នកទោស ដាក់ច្រើនលើសចំណុះនៅក្នុងមណ្ឌលឃុំឃាំង និងធានាលក្ខខណ្ឌនៃការឃុំខ្លួន ដែលគោរពសេចក្តីថ្លៃថ្នូររបស់អ្នកទោស ស្របតាមមាត្រា១០ នៃកតិកាសញ្ញានេះ។ រដ្ឋ ភាគី គួរធានាផងដែរ ឲ្យមានការស៊ើបអង្កេតឆាប់រហ័ស និងឯករាជ្យ និងផ្តន្ទា ទោស ជាយថាហេតុចំពោះមន្ត្រីរដ្ឋដែលទទួលខុសត្រូវចំពោះអំពើពុករលួយ ដាក់ ពន្ធនាគារ។ ម្យ៉ាងវិញទៀត រដ្ឋភាគី គួរធានាថា ចុងចោទ ត្រូវបានឃុំខ្លួនរង់ចាំ សវនាការ តែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះ ហើយ អនុវត្តជម្រើសផ្សេងៗជំនួស ឲ្យការដាក់ពន្ធនាគារ។ វិធានការបន្ទាន់ គួរត្រូវបានចាត់ ដើម្បីធានាទំនាក់ទំនង ឬ ការបញ្ជូនសាលក្រមស្ថាពររបស់តុលាការ ទៅអាជ្ញាធរពន្ធនាគារ និងសាមីជន ជាប់ឃុំ។*

*កុមារមានទំនាស់នឹងច្បាប់*

១៥. ទោះបីជាកត់សម្គាល់ឃើញព័ត៌មានដែលបានផ្តល់ជូនដោយគណៈប្រតិភូ ទាក់ទិននឹងស្ថាន ភាពនៃសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនិតិជនក៏ដោយ គណៈកម្មាធិការនេះមានការព្រួយបារម្ភ ពីភាពមិនមានប្រព័ន្ធយុត្តិធម៌អនិតិជន និងការពិតដែលថា កុមារជារឿយៗត្រូវឆ្លងកាត់នីតិវិធីដូច គ្នានឹងនីតិជនដែរ។ គណៈកម្មាធិការក៏មានកង្វល់ផងដែរលើការខកខានមិនបានធានាថា អនីតិជន ដែលជាប់ឃុំ ត្រូវបានឃុំខ្លួនដាច់ដោយឡែកពីនីតិជន (មាត្រា១០ ១៤ និង២៤)។

*រដ្ឋភាគីគួរតែចាត់វិធានការដើម្បីបង្កើតប្រព័ន្ធយុត្តិធម៌អនីតិជន ក្នុងគោលបំណង ធានាថា អនីតិជនត្រូវបានប្រព្រឹត្តិមកលើក្នុងរបៀបមួយសមស្រប តាមអាយុរបស់ ពួកគេ។ រដ្ឋភាគីគួរធានាផងដែរនូវការដាក់អនីតិជន និងនីតិជនឲ្យនៅដាច់ដោយ ឡែកពីគ្នានៅកន្លែងឃុំខ្លួន ដោយអនុលោមតាមបទដ្ឋានអន្តរជាតិ។*

*ការចាប់ខ្លួន និងការឃុំខ្លួនដោយបំពាន*

១៦. គណៈកម្មាធិការមានកង្វល់ទៅលើរបាយការណ៍អំពីការចាប់ខ្លួន និងការឃុំខ្លួនដោយបំពាន លើជនគ្មានផ្ទះសម្បែង អ្នកសុំទាន អ្នកប្រើប្រាស់គ្រឿងញៀន កុមារតាមចិញ្ចើមផ្លូវ និងអ្នករកស៊ីផ្លូវ ភេទ នៅក្នុងផ្នែក "សង្គមកិច្ច" យុវជននីតិសម្បទា និងមជ្ឈមណ្ឌលស្តារនីតិសម្បទាគ្រឿងញៀន។ វាគឺជាកង្វល់ជាពិសេសអំពីការចោទប្រកាន់ពីការធ្វើទារុណកម្ម ការធ្វើបាប និងការរំលោភបំពាន ផ្សេងទៀត ដែលប្រព្រឹត្តដោយបុគ្គលិកធ្វើការនៅស្ថាប័នទាំងនេះ (មាត្រា៧, ៩ និង ១០)។

*រដ្ឋភាគីគួរតែចាត់វិធានការចាំបាច់ទាំងអស់ដើម្បីបញ្ឈប់នូវការចាប់ខ្លួន និងការ ឃុំខ្លួនដោយបំពានលើជនគ្មានផ្ទះសម្បែង អ្នកសុំទាន អ្នកប្រើប្រាស់គ្រឿងញៀន កុមារតាមចិញ្ចើមផ្លូវ និងអ្នករកស៊ីផ្លូវភេទ។ រាល់ករណីនៃការធ្វើទារុណកម្ម និង ការធ្វើបាបទាំងអស់ គួរតែស៊ើបអង្កេត ហើយប្រសិនបើមានភ័ស្តុតាងពិតប្រាកដ បង្ហាញពីករណីទាំងនេះ គួរតែផ្តន្ទាទោស និងដាក់ទោសទណ្ឌ។*

*សិទ្ធិទទួលបានកិច្ចប្រឹក្សាយោបល់*

១៧. គណៈកម្មាធិការមានកង្វល់ថា ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ បុគ្គលដែលត្រូវបានចាប់ខ្លួន មានសិទ្ធិទទួលបានជំនួយពីមេធាវី បានតែបន្ទាប់ពីការឃាត់ខ្លួន ២៤ម៉ោងប៉ុណ្ណោះ។ គណៈកម្មា ធិការនេះក៏សម្តែងនូវកង្វល់ផងដែរលើកង្វះខាតមេធាវី ជាពិសេស នៅតាមបណ្តាខេត្តឆ្ងាយៗ និង សិទ្ធិទទួលបាននូវជំនួយផ្នែកច្បាប់របស់បុគ្គលដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ។ គណៈកម្មា ធិការនេះកត់សម្គាល់ថា កង្វះនៃសិទ្ធិទទួលបាននូវកិច្ចប្រឹក្សាយោបល់ក្នុងករណីទាំងនេះ អាចបង្ក ឲ្យមានឧប្បត្តិហេតុនៃការធ្វើទារុណកម្ម និងការធ្វើបាបលើបុគ្គលដែលបានឃាត់ខ្លួនទាំងនោះ (មាត្រា៩ និង១៤)។

*រដ្ឋភាគីគួរតែធានាថា គ្រប់ទិដ្ឋភាពច្បាប់ និងទន្ទាប់អនុវត្តរបស់ខ្លួនលើការឃុំខ្លួន បណ្តោះអាសន្ន ត្រូវមានសុខដុមនីយកម្មជាមួយនឹងលក្ខខណ្ឌតម្រូវនៃមាត្រា៩ និង ១៤ នៃកតិកាសញ្ញា ដូចមានចែងក្នុងសេចក្តីពន្យល់ទូទៅលេខ៣២ (២០០៧) ស្តីពី សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំ ជម្រះដោយយុត្តិធម៌*

*និងសេចក្តីពន្យល់ទូទៅលេខ៣៥ (២០១៤) ស្តីពីសេរីភាព និង សន្តិសុខរបស់មនុស្ស រាប់ទាំង តាមរយៈការអនុញ្ញាតឲ្យជនជាប់ឃុំដែលជាប់ចោទ ពីបទល្មើសព្រហ្មទណ្ឌអាចទទួលបានភ្លាមៗនូវសិទ្ធិទទួលបានជំនួយពីមេធាវី ចាប់ ពីដំណើរការដំបូងនៃការដកហូតសេរីភាពរបស់ខ្លួន។ ការទទួលបាននូវកិច្ចពិគ្រោះ យោបល់គួរតែត្រូវផ្តល់ឲ្យនៅគ្រប់ដំណាក់កាលទាំងអស់ នៃនីតិវិធីព្រហ្មទណ្ឌ។*

*ការជួញដូរមនុស្ស*

១៨. ទោះបីជាកត់សម្គាល់ឃើញមានកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋភាគីដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញ ដូរមនុស្សក៏ដោយ ក៏គណៈកម្មាធិការនេះមានកង្វល់អំពីការស៊ើបអង្កេត ដែលបានរាយការណ៍ថា មានការធ្វើឡើងតិចតួច ហើយការដាក់ទោស និងកង្វះទិន្នន័យផ្លូវការអំពីករណីទាំងឡាយ នៃការ ជួញដូរមនុស្ស (មាត្រា៨)។

*រដ្ឋភាគីគួរបង្កើន និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនឲ្យបានល្អប្រសើរ ជាងមុនក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងក៏គួរពិចារណាផងដែរអំពី ការបង្កើតទីភ្នាក់ងារកណ្តាលផ្លូវការដើម្បីទទួលខុសត្រូវចំពោះការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងតាមរយៈការស៊ើបអង្កេត និងការផ្តន្ទាទោសជនល្មើសជាប្រព័ន្ធ និងជាទូទៅ។ លើសពីនេះទៀត រដ្ឋភាគីគួរតែធានានូវកិច្ចការពារគ្រប់គ្រាន់ សំណង និងសំណងជំងឺចិត្ត ដល់ជនរងគ្រោះ រាប់ទាំងការស្តារនីតិសម្បទា។*

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

១៩. គណៈកម្មាធិការមានកង្វល់អំពីសេចក្តីរាយការណ៍ដែលថា មន្ត្រីជាន់ខ្ពស់នៃរដ្ឋភាគីបានធ្វើ សេចក្តីថ្លែងការណ៍ម្តងហើយម្តងទៀត ដែលជ្រៀតជ្រែកការប្រព្រឹត្តិទៅ និងឯករាជ្យភាពរបស់អង្គ ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) និងថាសេចក្តីថ្លែងការណ៍នេះបង្ហាញនូវការស្ទាក់ ស្ទើររបស់រដ្ឋភាគី ដើម្បីបន្តផ្តន្ទាទោសជនសង្ស័យបន្ថែមទៀត នៃឧក្រិដ្ឋកម្មប្រព្រឹត្តក្នុងអំឡុងរបប ខ្មែរក្រហម។ ក្នុងន័យនេះ គណៈកម្មាធិការកត់សម្គាល់លើការឆ្លើយតបរបស់រដ្ឋភាគីថា ខ្លួនមិន បានជ្រៀតជ្រែកកិច្ចដំណើរការនីតិវិធីរបស់តុលាការនៃ អ.វ.ត.ក ទេ និងខ្លួនស្វាគមន៍ចំពោះការ សន្យាអះអាងរបស់ខ្លួនដែលបានផ្តល់ឱ្យក្នុងអំឡុងពេលកិច្ចពិភាក្សាថា ទោះនាពេលអនាគត ក៏មិន ការជ្រៀតជ្រែកដែរ (មាត្រា ១៤)។

*រដ្ឋភាគីគួរចាត់វិធានការដើម្បីការពារឯករាជ្យភាពពេញលេញនៃអ.វ.ត.ក និង បានសហការជាមួយ ECCC ក្នុងការបំពេញមុខងាររបស់ខ្លួន។*

*ឯករាជ្យភាពនៃប្រព័ន្ធតុលាការ*

២០. គណៈកម្មាធិការមានកង្វល់អំពីកង្វះនៃប្រព័ន្ធតុលាការឯករាជ្យ មិនលំអៀង និងមានការ សោកស្តាយចំពោះការចោទប្រកាន់ជាច្រើនអំពីអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការនេះ។ គណៈ កម្មាធិការនេះបានកត់សម្គាល់ដោយកង្វល់ថា ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម (SCM) ដែលបានអនុម័តនៅឆ្នាំ២០១៤ មិនបង្កើតបាននូវការធានាការពារគ្រប់ គ្រាន់នូវឯករាជ្យភាពរបស់តុលាការឡើយ (មាត្រា១៤)។

*រដ្ឋភាគីគួរចាត់វិធានការបន្ទាន់នានាដើម្បីធានា និងការពារឯករាជ្យភាពពេញលេញ និងភាពមិនលំអៀងនៃប្រព័ន្ធតុលាការ និងការធានាថា ប្រព័ន្ធតុលាការនេះដំណើរ ការដោយសេរី ដោយគ្មានការដាក់សម្ពាធ និងការជ្រៀតជ្រែកពីអង្គនីតិប្រតិបត្តិ។ វា គួរតែធ្វើការពិនិត្យឡើងវិញនូវច្បាប់ទាំងស្តីពីប្រព័ន្ធតុលាការ ដើម្បីកាត់បន្ថយសមត្ថ កិច្ចរបស់ក្រសួងយុត្តិធម៌ និងពង្រឹងឯករាជ្យភាពរបស់តុលាការ។*

*សេរីភាពនៃការសម្តែងមតិ និងការបង្កើតសមាគម*

២១. គណៈកម្មាធិការមានកង្វល់អំពីរបាយការណ៍នៃការសម្លាប់អ្នកកាសែត អ្នកការពារសិទ្ធិ មនុស្ស និងតួអង្គសង្គមស៊ីវិលផ្សេងៗទៀត។ គណៈកម្មាធិការនេះក៏មានកង្វល់ផងដែរអំពីរបាយ ការណ៍នៃការយាយី និងការបំភិតបំភ័យដល់អ្នកកាសែត អ្នកការពារសិទ្ធិមនុស្ស សហជីពកម្មករ សកម្មជនដីធ្លី និងបរិស្ថាន ព្រមទាំងតួអង្គសង្គមស៊ីវិលដទៃទៀត ក៏ដូចជាសមាជិកនៃគណបក្ស ប្រឆាំង ដែលនៅតែបន្តត្រូវគេផ្តន្ទាទោសចំពោះសកម្មភាពរបស់ពួកគេ ជាពិសេស តាមរយៈការ ដាក់ជាទោសព្រហ្មទណ្ឌចំពោះបទល្មើសបរិហារកេរ្តិ៍ និងបទល្មើសដែលច្បាប់មិនមានចែងច្បាស់ លាស់ផ្សេងទៀត។ លើសពីនេះទៅទៀត គណៈកម្មាធិការមានកង្វល់អំពីការរឹតត្បិតលើសេរីភាព នៃការបញ្ចេញមតិដែលកំណត់ដោយច្បាប់ដែលបានធ្វើវិសោធនកម្មស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ទោះបីគណៈកម្មាធិការកត់សម្គាល់ដោយកោតសរសើរថា ទំនាក់ទំនងតាមអន ឡាញ និងសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលត្រូវបានរីវឌ្ឍន៍ទៅមុខដោយរលូននៅក្នុងរដ្ឋភាគី ក៏ដោយ ក៏គណៈកម្មាធិការមានកង្វល់អំពីសេចក្តីរាយការណ៍ដែលថា សេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្ម តាមអ៊ីនធឺណិត និងសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចមានបទ ប្បញ្ញត្តិដាក់ការរិតត្បិត លើទំនាក់ទំនងតាមអនឡាញ និងដាក់ការរឹតត្បិតហួសហេតុលើអង្គការមិន មែនរដ្ឋាភិបាល (មាត្រា៦, ៧, ១៩ និង២២)។

*រដ្ឋភាគីគួរធានាថា បុគ្គលគ្រប់រូបអាចអនុវត្តដោយសេរីនូវសិទ្ធិសេរីភាពបញ្ចេញមតិ និងការបង្កើតសមាគមរបស់ពួកគេ អនុលោមតាមមាត្រា១៩ និង២២ នៃកតិកាសញ្ញា និងសេចក្តីពន្យល់ទូទៅលេខ៣៤ (២០១១) របស់គណៈកម្មាធិការនេះ ស្តីពីសេរីភាព នៃគំនិត និងការសម្តែងមតិ។ ដោយធ្វើដូចនេះ រដ្ឋភាគីគួរតែ៖*

(ក) ចាត់វិធានការជាបន្ទាន់ដើម្បីស៊ើបអង្កេតពាក្យបណ្តឹងនៃការសម្លាប់ និងការ ផ្តល់កិច្ចការពារដ៏មានប្រសិទ្ធភាពដល់អ្នកកាសែត អ្នកការពារសិទ្ធិមនុស្ស និងតួអង្គ សង្គមស៊ីវិលផ្សេងៗទៀតដែលត្រូវបានទទួលរងនូវការបំភិតបំភ័យនិងការវាយប្រហារ នានាដោយសារតែសកម្មភាពវិជ្ជាជីវៈរបស់ពួកគេ

(ខ) ចៀសវាងពីការផ្តន្ទាទោសអ្នកកាសែត អ្នកការពារសិទ្ធិមនុស្ស និងតួអង្គ សង្គមស៊ីវិលផ្សេងៗទៀត ដែលយកការផ្តន្ទាទោសនេះជាមធ្យោបាយនៃការធ្វើឲ្យ ញញើត ឬបង្អាក់ទឹកចិត្តដល់ពួកគេពីការសម្តែងមតិរបស់ពួកគេដោយសេរី

(គ) ចូរពិចារណាកុំដាក់បទបរិហាកេរ្តិ៍ ជាទោសព្រហ្មទណ្ឌ និងលើកយកនូវបទប្បញ្ញត្តិពាក់ព័ន្ធណាមួយផ្សេងទៀតនៃក្រមព្រហ្មទណ្ឌ ឲ្យស្របទៅនឹងមាត្រា១៩ នៃកតិកាសញ្ញានេះ

(ឃ) ពិនិត្យឡើងវិញនូវច្បាប់បច្ចុប្បន្ន និងច្បាប់មិនទាន់តាក់តែងឡើងរបស់ខ្លួន រាប់ទាំងសេចក្តីព្រាងច្បាប់ស្តីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត និងច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល ដើម្បីបញ្ចៀសនូវការប្រើប្រាស់វាក្យសព្ទមិនច្បាស់លាស់ និងការរឹតត្បិតហួសហេតុ ដើម្បីធានាថា ការរឹតត្បិតណាមួយលើការអនុវត្តសេរីភាព នៃការបញ្ចេញមតិ និងការបង្កើតសមាគម ពិតជាអនុលោមតាមលក្ខខណ្ឌតម្រូវនៃ មាត្រា១៩ កថាខណ្ឌទី៣ និង២២ នៃកតិកាសញ្ញានេះ។

## សិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី

២២. គណៈកម្មាធិការមានកង្វល់ អំពីការកើនឡើងនូវរបាយការណ៍នៃការចាប់ខ្លួនបាតុករ ដោយបំពាន និងទម្លាប់អនុវត្តដែលតម្រូវឱ្យពួកគេផ្តិតមេដៃលើឯកសារដោយត្រូវសន្យាថានឹងមិនធ្វើ បាតុកម្មទៀតទេនាពេលអនាគត (មាត្រា២១)។

រដ្ឋភាគីគួរធានាថា ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវបានអនុវត្ត អនុលោម តាមកតិកាសញ្ញានេះ។ រដ្ឋភាគីក៏គួរតែធានាផងដែរថា ការអនុវត្តនូវសិទ្ធិនៃការជួប ប្រជុំដោយសន្តិវិធី មិនត្រូវមានការរឹតត្បិតផ្សេងៗ ក្រៅពីការរិតត្បិតដែលអនុញ្ញាត ឲ្យមាន ក្រោមកតិកាសញ្ញានេះឡើយ។

## សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ និងសមភាពរបស់សហព័ន្ធ

២៣. គណៈកម្មាធិការមានកង្វល់ថា មាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី ចែងថាស្ត្រីម្នាក់មិនត្រូវរៀបអាពាហ៍ពិពាហ៍ម្តងទៀតទេ រហូតដល់១២០ថ្ងៃ បានកន្លងទៅ គិចចាប់ពីថ្ងៃនៃការរំលាយ ឬមោឃ ភាពអាពាហ៍ពិពាហ៍មុនរបស់នាង។ គណៈកម្មាធិការនេះ ក៏មានកង្វល់ផងដែរលើបទបញ្ជាមួយ ដែលបានចេញដោយក្រសួងការបរទេស ដែលរឹតត្បិតសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍រវាងបុរស និងបុរស

បរទេសនិងស្ត្រីកម្ពុជាដោយសម្អាងលើមូលដ្ឋាននៃអាយុនិងប្រាក់ចំណូលរបស់បុរសនោះ (មាត្រា៣, ២៣ និង២៦)។

*រដ្ឋភាគីគួរលុបចោលបទប្បញ្ញត្តិ ដែលរើសអើង ឈរលើហេតុផល ភេទ អាយុ និង ប្រាក់ចំណូល ទាក់ទងទៅនឹងអាពាហ៍ពិពាហ៍។*

## *ទណ្ឌកម្មលើរាងកាយ*

២៤. ទោះបីជាទទួលស្គាល់ថា ការដាក់ទណ្ឌលើរាងកាយត្រូវបានហាមប្រាមនៅក្នុងសាលារៀន និងប្រព័ន្ធដាក់ទោសទណ្ឌក៏ដោយ គណៈកម្មាធិការនេះមានកង្វល់ថា ការប្រើប្រាស់ការដាក់ទណ្ឌ កម្មនេះនៅតែស្របច្បាប់នៅតាមផ្ទះ ជាកន្លែងដែលវាបន្តទទួលយក និងអនុវត្តជាលក្ខណៈប្រពៃ ណីដោយឪពុកម្តាយ និងអាណាព្យាបាល ថាជាទម្រង់មួយនៃវិន័យ (មាត្រា៧ និង២៤)។

*រដ្ឋភាគីគួរចាត់វិធានការជាក់ស្តែង ដោយរាប់ទាំងតាមរយៈវិធានការច្បាប់ តាមការ ចាំបាច់ ដើម្បីបញ្ចប់ការដាក់ទណ្ឌកម្មលើរាងកាយ នៅគ្រប់ទីកន្លែងទាំងអស់។ គួរ លើកទឹកចិត្តរាល់ទម្រង់វិន័យអហិង្សាទាំងអស់ ធ្វើជាជម្រើសក្នុងការដាក់ទណ្ឌកម្ម លើរាងកាយ និងគួរធ្វើយុទ្ធនាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈដើម្បីលើក កម្ពស់ការយល់ដឹងអំពីផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់នៃការដាក់ទណ្ឌកម្មលើរាងកាយនេះ។*

## *ការចូលរួមក្នុងកិច្ចការសាធារណៈ*

២៥. គណៈកម្មាធិការកត់សម្គាល់ដោយកង្វល់ថា ច្បាប់ពីរដែលបានធ្វើវិសោធនកម្មរួច គឺទាក់ទង នឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបាន អនុម័តនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ ដោយពុំមានកិច្ចពិគ្រោះយោបល់ពិតប្រាកដ ដែលដំណើរ ការស្រដៀងគ្នានេះ ច្បាប់ជាមូលដ្ឋានចំនួនបី ស្តីពីប្រព័ន្ធតុលាការ ត្រូវបានអនុម័តនៅខែឧសភា ឆ្នាំ២០១៤។ ទោះបីជាមានការកត់សម្គាល់លើគោលបំណងរបស់រដ្ឋភាគី ដើម្បីអនុម័តច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក៏ដោយ ក៏គណៈកម្មាធិការកត់សម្គាល់ដោយកង្វល់អំពី កង្វះតម្លាភាពនៅក្នុងដំណើរការអង្គនីតិបញ្ញត្តិ នៅក្នុងរដ្ឋភាគី ដូចបានធានាដោយមាត្រា២៥ នៃ កតិកាសញ្ញានេះ (មាត្រា២៥)។

*រដ្ឋភាគីគួរតែធានាឱ្យបាននូវតម្លាភាពក្នុងដំណើរការអង្គនីតិបញ្ញត្តិ និងគួរតែពិចារ ណាលើការធ្វើសេចក្តីព្រាងច្បាប់ទាំងឡាយ ឲ្យសាធារណៈជនបានដឹង ដើម្បីងាយ ស្រួលឲ្យប្រជាពលរដ្ឋ ជជែកដេញដោល និងធ្វើកិច្ចសន្ទនាជាសាធារណៈ ជាមួយ តំណាងរបស់ពួកគេ ដោយត្រូវគិតគូរអំពីសេចក្តីពន្យល់ទូទៅលេខ២៥ (១៩៩៦) របស់គណៈកម្មាធិ*

*ការនេះ ស្តីពីសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ សិទ្ធិបោះឆ្នោត និងសិទ្ធិទទួលបានស្មើភាពគ្នានូវសេវាសាធារណៈ។*

*សិទ្ធិបោះឆ្នោត*

២៦. គណៈកម្មាធិការចាត់ទុកថា ការបដិសេធជាទូទៅលើសិទ្ធិបោះឆ្នោតរបស់ទណ្ឌិត មិនបំពេញ តាមលក្ខខណ្ឌតម្រូវនៃមាត្រា១០ កថាខ័ណ្ឌទី៣ ដែលបានចែងពាក់ព័ន្ធនឹងមាត្រា២៥ នៃកតិកា សញ្ញានេះ។ គណៈកម្មាធិការនេះមានកង្វល់ផងដែរអំពីការរឹតត្បិតលើសិទ្ធិបោះឆ្នោតសម្រាប់ជន មានសតិវិបល្លាសមួយចំនួន (មាត្រា២, ១០, ២៥ និង២៦)។

*រដ្ឋភាគីគួរពិនិត្យឡើងវិញនូវច្បាប់របស់ខ្លួន ដែលបដិសេធសិទ្ធិបោះឆ្នោតរបស់ ទណ្ឌិតទាំងអស់ ក្រោយពេលពិចារណាលើកថាខ័ណ្ឌ១៤ នៃសេចក្តីពន្យល់ទូទៅ របស់គណៈកម្មាធិការនេះ លេខ២៥ (១៩៩៦) លើមាត្រា២៥ (ការចូលរួមក្នុងកិច្ចការ សាធារណៈ និងសិទ្ធិបោះឆ្នោត)។ រដ្ឋភាគីក៏គួរតែធានាផងដែរថា ច្បាប់របស់ខ្លួនមិន បានរើសអើងប្រឆាំងនឹងជនមានសតិវិបល្លាស ដោយបដិសេធនូវសិទ្ធិបោះឆ្នោត របស់ពួកគេ ឈរលើមូលដ្ឋានដែលមានការទាក់ទងតិចតួច ឬដែលមិនមានទំនាក់ ទំនងសមហេតុផល និងជាសត្យានុម័ត ទៅនឹងសមត្ថភាពក្នុងការបោះឆ្នោតរបស់ពួក គេ ដោយត្រូវគិតគូរពិចារណាលើមាត្រា២៥ នៃកតិកាសញ្ញានេះ។*

*បុគ្គលគ្មានរដ្ឋ*

២៧. គណៈកម្មាធិការមានកង្វល់អំពីស្ថានភាពរបស់ខ្មែរក្រោម និងជាតិពិន្ទុវៀតណាមដែលបាន និងកំពុងរស់នៅក្នុងប្រទេសកម្ពុជា ជាច្រើនជំនាន់មកហើយ ដែលតែជាជនគ្មានរដ្ឋ ឬកង្វះឯកសារ អត្តសញ្ញាណកម្ពុជា។ គណៈកម្មាធិកានេះ មានកង្វល់បន្ថែមទៀតអំពីកិច្ចរក្សាការពារមិនគ្រប់គ្រាន់ ដើម្បីធានាថា កុមារដែលកើតនៅក្នុងប្រទេសកម្ពុជា បើសិនជាពួកគេមិនមានរដ្ឋទេនោះ ត្រូវទទួល បានសញ្ជាតិ និងឯកសារអត្តសញ្ញាណកម្ម (មាត្រា២, ២៤ និង២៦)។

*រដ្ឋភាគីទាំងអស់គួរតែយកវិធានការចាំបាច់ដើម្បីធានាឱ្យបាននូវការទទួលបានសិទ្ធិពេញលេញពីកតិកាសញ្ញានេះដោយអ្នករស់នៅទាំងអស់ រាប់ទាំងបុគ្គលគ្មានរដ្ឋផង។*

*រដ្ឋភាគីក៏គួរតែជួយសម្រួលផងដែរដល់ការទទួលបាននូវសំណុំឯកសារអត្តសញ្ញាណ កម្ម។ លើសពីនេះទៀត រដ្ឋភាគីគួរតែធានាសិទ្ធិកុមារគ្មានរដ្ឋ ដែលបានកើតនៅលើ ទឹកដីនៃប្រទេសកម្ពុជា ចំពោះឪពុកម្តាយកុមារគ្មានរដ្ឋទាំងនេះ ដើម្បីទទួលបាន សញ្ជាតិមួយ។*

### *សិទ្ធិរបស់បុគ្គលជនជាតិភាគតិច*

២៨. ទោះបីជាទទួលស្គាល់ក្របខ័ណ្ឌគតិយុត្តិដែលមានស្រាប់ក៏ដោយ ក៏គណៈកម្មាធិការ នៅតែ មានកង្វល់ថា ជនជាតិដើមភាគតិចមិនត្រូវបានគេលើកយកមកពិគ្រោះយោបល់គ្រប់គ្រាន់ ក្នុង ដំណើរការធ្វើសេចក្ដីសម្រេច ទាក់ទិននឹងបញ្ហានានាដែលប៉ះពាល់ដល់សិទ្ធិរបស់គេ រាប់ទាំងការ គ្រប់គ្រងដីសហគមន៍របស់ពួកគេ និងបែងចែកដីសម្រាប់ឧស្សាហកម្មទាញយករ៉ែ និងកសិ ពាណិជ្ជកម្ម។ ក្នុងន័យនេះ សម្បទានដីដែលពួកគេទាមទា នៅតែបន្តត្រូវបានផ្ដល់សម្រាប់ការប្រើ ប្រាស់ឯកជន។ គណៈកម្មាធិការនេះក៏បានកត់សម្គាល់ដោយកង្វក់ផងដែរ អំពីរបាយការណ៍ដែល ថា ជនជាតិដើមភាគតិចដែលមានបញ្ហាពាក់ព័ន្ធជាមួយរដ្ឋាភិបាលក្នុងការការពារសិទ្ធិរបស់ពួកគេ នឹងប្រឈមមុខនឹងឧបសគ្គជាក់ស្ដែងជាច្រើន។

*រដ្ឋភាគីគួរតែបង្កើតយន្តការពិគ្រោះយោបល់មួយដែលមានប្រសិទ្ធភាព និងជានា បានទូវការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយនឹងជនជាតិដើមភាគតិចក្នុងការធ្វើការសម្រេចចិត្តនៅក្នុងគ្រប់វិស័យទាំងអស់ដែលមានផលប៉ះពាល់លើសិទ្ធិ របស់ពួកគេ។*

### *ការផ្សព្វផ្សាយព័ត៌មានដែលទាក់ទងទៅនឹងកតិកាសញ្ញានេះ*

២៩. រដ្ឋភាគីគួរតែផ្សព្វផ្សាយឲ្យបានយ៉ាងទូលំទូលាយនូវកតិកាសញ្ញានេះ អត្ថបទនៃរបាយ ការណ៍តាមកាលកំណត់លើកទីពីររបស់ខ្លួន ការឆ្លើយតបជាលាយលក្ខណ៍អក្សរ ទៅនឹងបញ្ជីនៃ សំណួរដែលបានធ្វើឡើងដោយគណៈកម្មាធិការ និងការពិនិត្យផ្ទៀងផ្ទាត់ចុងក្រោយ ក្នុងចំណោម អាជ្ញាធរតុលាការ អាជ្ញាធរច្បាប់ និងអាជ្ញាធររដ្ឋបាល សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល នានា ដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាសាធារណជន។

៣០. អនុលោមតាមវិធាន៧១ កថាខ័ណ្ឌទី៥ នៃវិធាននីតិវិធីរបស់គណៈកម្មាធិការ រដ្ឋភាគីគួរផ្ដល់ ក្នុងអំឡុងពេលមួយឆ្នាំ នូវព័ត៌មានដែលពាក់ព័ន្ធស្ដីពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការ ដែលបានធ្វើឡើងនៅក្នុងកថាខណ្ឌ១១, ១៣ និង២១ ខាងលើ។

៣១. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីដាក់របាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួននៅ ថ្ងៃទី ២ ខែមេសា ឆ្នាំ២០១៩ និងត្រូវបញ្ចូលព័ត៌មានបច្ចុប្បន្នភាពជាក់លាក់ ស្ដីពីការអនុវត្តនូវអនុ សាសន៍ទាំងអស់របស់ខ្លួន ព័ត៌មានស្ដីពីកតិកាសញ្ញាទាំងមូល។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីធ្វើ ការរៀបចំរបាយការណ៍នេះ ដើម្បីពិគ្រោះឲ្យបានទូលំទូលាយជាមួយសង្គមស៊ីវិល និងអង្គការមិន មែនរដ្ឋាភិបាលដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។ យោងតាមសេចក្ដីសម្រេចរបស់ មហាសន្និបាតលេខ ៦៨/២៦៨ ពាក្យដែលកំណត់សម្រាប់របាយការណ៍នេះ គឺមានចំនួនមិនលើស ពី ២១.២០០ ពាក្យ។